# ព្រឹត្តិបត្រព័ត៌មាន

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)

## គ.ជ.ប NEC BULLETIN

លេខ ៩ ចេញផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

Issue 9 : 10 / 8 / 2023


# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

## ប្រធាន គ.ជ.ប ថ្លែងអំណរគុណដល់អ្នកសង្កេតការណ៍អន្តរជាតិ ដែលបានចូលរួម សង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប**

ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ វត្តមានអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ និងតំណាងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជាទាំងអស់ ដែលអញ្ជើញមកសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



**តទៅទំព័រទី២**

**មាតិកា៖** **ទំព័រ**


- ប្រធាន គ.ជ.ប ថ្លែងអំណរគុណដល់អ្នកសង្កេតការណ៍អន្តរជាតិ ដែលបានចូលរួមសង្កេតការណ៍បោះឆ្នោត ...............១
- ប្រធាន គ.ជ.ប ទទួលជួបគណៈប្រតិភូសហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច ...............................................៣
- លទ្ធផលនៃការបែងចែកអាសនៈក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ តាមមណ្ឌល .....៦
- បញ្ជីរាយនាមបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ........................................................៧
- លទ្ធផលសវនាការជាសាធារណៈដោះស្រាយពាក្យបណ្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់គណៈកម្មការ ...............១២
- គ.ជ.ប បានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជាក់ភាពត្រឹមត្រូវលើលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ..................១៥
- ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយមានការចូលរួមសង្កេតមើល..១៦

តមកពីទំព័រទី១ **ប្រធាន គ.ជ.ប ...**

នៅកម្ពុជា។

ការថ្លែងអំណរគុណរបស់ឯកឧត្តមប្រធាន គ.ជ.ប ធ្វើឡើងក្នុងឱកាសឯកឧត្តមអញ្ជើញជាអធិបតីក្នុងពិធីលៀងសាយ-ភោជនជាមួយភាគីពាក់ព័ន្ធ ដែលរៀបចំដោយ គ.ជ.ប នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៧:០០យប់។

នាឱកាសនោះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍ថា ការរៀបចំការបោះឆ្នោតមិនមែនជាការងារងាយស្រួលទេ ព្រោះដើម្បីឱ្យការបោះឆ្នោតមួយសម្រេចបានជោគជ័យ គឺត្រូវមានកត្តាច្រើនដូចជា ត្រូវមានច្បាប់ បទបញ្ញា និងនីតិវិធីច្បាស់លាស់ ក្រមសីលធម៌ ធនធានមនុស្ស ធនធានថវិកាគ្រប់គ្រាន់ និងត្រូវមានការចូលរួមរបស់ភាគីពាក់ព័ន្ធនានាក្នុងដំណើរការបោះឆ្នោត



**សកម្មភាពក្នុងពិធីលៀងសាយភោជន**

ហើយក៏គ្មានការបោះឆ្នោតនៅប្រទេសណាមួយលើសកលលោកដែលល្អឥតខ្ចោះនោះដែរ។

ឯកឧត្តមបានមានប្រសាសន៍បន្ថែមថា ក្នុងនាមជាប្រធាន គ.ជ.ប ក្នុងនាមឯកឧត្តមផ្ទាល់ និងប្រជារាស្ត្រខ្មែរទូទាំងប្រទេស ដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស គឺមានបំណង




**សកម្មភាពថតរូបអនុស្សាវរីយ៍**

ប្រាថ្នាចង់បានការបោះឆ្នោតមួយដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលគ្រប់ភាគីទាំងអស់អាចទទួលយកបាន។

ឯកឧត្តមបានគូសបញ្ជាក់ថា ដើម្បីសម្រេចបំណងប្រាថ្នាដ៏ចម្បងនេះ គ.ជ.ប ត្រូវគោរពស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ពាក់ព័ន្ធជាធរមាន និងគោលការណ៍អន្តរជាតិ ដែលកំណត់ថា ការគ្រប់-គ្រងការបោះឆ្នោតត្រូវតែអនុវត្តឱ្យបាននូវគោលការណ៍ជាមូល-ដ្ឋាន ចំនួន ៧ រួមមាន៖ ឯករាជ្យភាព អព្យាក្រឹតភាព សុចរិតភាព តម្លាភាព ប្រសិទ្ធភាព វិជ្ជាជីវៈ និងភាពជាអ្នកបម្រើសេវា។ ហេតុនេះហើយបានជា គ.ជ.ប តែងតែសម្រេចបាននូវការរៀបចំការបោះឆ្នោតដោយខ្លួនឯង និងជាទៀងទាត់តាមកាលកំណត់នៃច្បាប់។ ហើយលទ្ធផលជាក់ស្តែងមួយដែលទើបសម្រេចបាននោះ គឺបើតាមលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ អ្នកចេញទៅបោះឆ្នោតមានចំនួន ៨៤,៥៩ ភាគរយ នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុប ដែលជាចំនួនមួយកើនឡើងបើធៀបនឹងការបោះឆ្នោតកន្លងមក។

ក្នុងពិធីលៀងសាយភោជននេះ គ.ជ.ប ក៏បានផ្តល់វិញ្ញាបនបត្រ និងវត្ថុអនុស្សាវរីយ៍ដល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិផងដែរ៕







**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប ផ្តល់វិញ្ញាបនបត្រ និងវត្ថុអនុស្សាវរីយ៍ដល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ**

# ប្រធាន គ.ជ.ប ទទួលជួបគណៈប្រតិភូសហគមន៍សេដ្ឋកិច្ច នៃរដ្ឋអាហ្វ្រិកខាងលិច

នារសៀលថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៦:០០ នៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានទទួលជួប ឯកឧត្តម **រ៉េម៉ាន់ដូ ភីរ៉េរ៉ា** (H.E.Mr. Raimundo PEREIRA) ប្រធានគណៈប្រតិភូសហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច (La Communauté économique des États de L’Afrique de L’Ouest “CEDEAO”) និងជាសមាជិកបណ្ដាញពង្រឹងសមត្ថភាពរៀបចំការបោះឆ្នោតនៃប្រទេសនិយាយភាសាបារាំង ដែលបានមកសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។



សកម្មភាពក្នុងជំនួបពិភាក្សា

ជាកិច្ចចាប់ផ្ដើម ឯកឧត្តម **ប្រាជ្ញ ចន្ទ** មានមតិស្វាគមន៍ គណៈប្រតិភូស៊ីឌីអេអូ (CEDEAO) ដែលបានអញ្ជើញមកដល់ ទីស្ដីការ គ.ជ.ប និងមានចំណាប់អារម្មណ៍អំពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។

បន្ទាប់មក ឯកឧត្តម **រ៉េម៉ាន់ដូ ភីរ៉េរ៉ា** បានថ្លែងអំណរគុណ ដល់ ឯកឧត្តម **ប្រាជ្ញ ចន្ទ** និងបានកោតសរសើរដល់ គ.ជ.ប ដែល បានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នេះ ប្រព្រឹត្តទៅបានលទ្ធផលល្អ។ លទ្ធផលនៃការងារនេះ ស្ដែង ចេញពីការបំពេញភារកិច្ចរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់



(រូបខាងស្ដាំ)ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប និងឯកឧត្តម រ៉េម៉ាន់ដូ ភីរ៉េរ៉ា ប្រធានគណៈប្រតិភូសហគមន៍ សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច

ប្រកបដោយវិជ្ជាជីវៈ។ ឯកឧត្តម បានសង្កេតឃើញថា ការបោះ-ឆ្នោតនេះប្រព្រឹត្តទៅដោយភាពស្ងប់ស្ងាត់ សន្តិភាព សេរី មានតម្លាភាព និងមានការចូលរួមយ៉ាងផុលផុសពីប្រជាពលរដ្ឋកម្ពុជា។ ឯកឧត្តម បានបន្តថា អង្គការស៊ីឌីអេអូ (CEDEAO) ធ្លាប់ផ្លាស់ប្ដូរបទពិសោធន៍ជាមួយបណ្ដាប្រទេសផ្សេងៗជាច្រើនរួចមក ហើយ អង្គការស៊ីឌីអេអូ (CEDEAO) ក៏មានបំណងចង់ផ្លាស់ប្ដូរកិច្ចការបោះឆ្នោតជាមួយព្រះរាជាណាចក្រកម្ពុជាផងដែរ។ ឯកឧត្តមសង្កេតឃើញថា ប្រជាធិបតេយ្យនៅកម្ពុជាមានភាពចាស់ទុំ ហើយឯកឧត្តមចង់ឱ្យមានការពង្រឹងបន្ថែមទៀត ដោយមានការចូលរួមបោះឆ្នោតពីប្រជាពលរដ្ឋដែលនៅក្រៅប្រទេស។



សកម្មភាពក្នុងជំនួបពិភាក្សា



សកម្មភាពក្នុងជំនួបពិភាក្សា

ឯកឧត្តមប្រធាន គ.ជ.ប បានថ្លែងអំណរគុណដល់គណៈប្រតិភូស៊ីឌីអេអូ (CEDEAO) ដែលបានវាយតម្លៃចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។ ឯកឧត្តមបន្តថា ប្រវត្តិនៃការបោះឆ្នោតនៅកម្ពុជា មានជាង ៣០ ឆ្នាំ មកហើយ ដែលបានបន្តរហូតមកដល់ពេលនេះ គឺបានរៀបចំការបោះឆ្នោតយ៉ាងទៀងទាត់។ ប្រវត្តិសាស្ត្រកម្ពុជាពោរពេញទៅដោយសង្គ្រាមស៊ីវិល ដែលមានបរទេសនៅពីក្រោយដែលជាហេតុជំរុញឱ្យមានសង្គ្រាមផ្ទៃក្នុង។ បន្ទាប់មក ភាគីជម្លោះទាំងអស់បានឯកភាពគ្នាបញ្ចប់សង្គ្រាម ដោយបានបង្កើតកិច្ចព្រមព្រៀងទីក្រុងប៉ារីស រហូតដល់បង្កើតឱ្យមានការបោះឆ្នោត ដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) នៅឆ្នាំ១៩៩៣ ដែលការបោះឆ្នោតនាពេលនោះជ្រើសរើសសភាធម្មនុញ្ញ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ បន្ទាប់មកសភាធម្មនុញ្ញក្លាយជាសភាជាតិ ដើម្បីបង្កើតរាជរដ្ឋាភិបាលស្របច្បាប់។ រដ្ឋធម្មនុញ្ញបានចែងថា ព្រះរាជាណាចក្រកម្ពុជាប្រកាន់យករបបប្រជាធិបតេយ្យ សេរី ពហុបក្ស។ ឯកឧត្តមបន្តថា ចាប់ពីឆ្នាំ១៩៩៨ មក កម្ពុជារៀបចំការបោះឆ្នោតដោយខ្លួនឯង ដែលចាត់ចែងដោយ គ.ជ.ប ហើយរហូតមកដល់បច្ចុប្បន្ន គ.ជ.ប បានរៀបចំការបោះឆ្នោតយ៉ាងទៀងទាត់ ទាំងសកល ទាំងអសកល ចំនួន ១៧ លើក រួចមកហើយ។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានបន្តទៀតថា បច្ចុប្បន្ន គ.ជ.ប ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលមានសមត្ថកិច្ចរបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។ ឯកឧត្តមបន្តថា ពីមុនការបោះឆ្នោតនៅកម្ពុជាជួបបញ្ហាខ្លះដែរ ប៉ុន្តែចាប់ពីឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន ការបោះឆ្នោតពុំមានបញ្ហាអ្វីទេ ដូចជាបញ្ហាអសន្តិសុខ ការតវ៉ាតាមទីសាធារណៈក្រោយការបោះឆ្នោតជាដើម ដោយសារការបោះឆ្នោតនៅកម្ពុជាបានធ្វើការកែលម្អជាបន្តបន្ទាប់ ដូចជាការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតជាដើម។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនបន្តទៀតអំពីដំណាក់កាលនៃការរៀបចំការបោះឆ្នោតនៅកម្ពុជាមាន ៤ ដំណាក់កាល។ ឯកឧត្តមបានពន្យល់ដោយសង្ខេបនូវដំណាក់កាលនីមួយៗ នៃដំណើរការរៀបចំការបោះឆ្នោត ដែលមានដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដំណាក់កាលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដំណាក់កាលនៃការឃោសនាបោះឆ្នោត និងដំណាក់កាលនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបែងចែកអាសនៈ និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។ ឯកឧត្តមបានបញ្ជាក់បន្ថែមអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតថា ជាដំបូងគណបក្សនយោបាយត្រូវមានឈ្មោះស្របច្បាប់នៅក្រសួងមហាផ្ទៃ ទើបមានសិទ្ធិដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ នៅ គ.ជ.ប ដោយអនុវត្តតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។ គណបក្សនយោបាយ ចំនួន ២ ត្រូវបាន គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញបដិសេធ ដោយហេតុផលមិនបានបំពេញតាមលក្ខខណ្ឌនៃច្បាប់កំណត់។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧នេះ មានតែ ១៨ គណបក្សចូលរួមប្រកួតប្រជែង។

ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនថា គណបក្សនយោបាយទាំង ១៨ មានសិទ្ធិធ្វើការឃោសនាបោះឆ្នោត រយៈពេល ២១ ថ្ងៃ ដោយអនុវត្តទៅតាមនីតិវិធី។ រូបភាពនៃការឃោសនាបោះឆ្នោតមានច្រើនដូចជាការហែក្បួន ការជួបប្រជុំ ចែកខិត្តប័ណ្ណ ចុះឃោសនាតាមផ្ទះប្រជាពលរដ្ឋ ។ល។

ចំពោះការបោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនថា ប្រតិបត្តិការបោះឆ្នោតចាប់ផ្តើមនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល។ ចប់ការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅក្នុងការិយាល័យបោះឆ្នោតនោះតែម្តង។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ មានសិទ្ធិសង្កេតមើលដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនេះរហូតដល់ចប់។ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ត្រូវបានបិទផ្សាយ មួយច្បាប់នៅមុខការិយាល័យរាប់សន្លឹកឆ្នោត រួចផ្ញើមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មួយច្បាប់ ដើម្បីបញ្ជូនបន្តមក គ.ជ.ប ធ្វើការផ្សព្វផ្សាយ។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ មានសិទ្ធិថតកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងមកទទួលយក ទ.១១០២ នៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនបន្តទៀតថា ទោះបីមានចលនារារាំងប្រជាពលរដ្ឋ ញុះញង់ប្រជាពលរដ្ឋឱ្យបំផ្លាញការបោះឆ្នោត ប៉ុន្តែប្រជាពលរដ្ឋបានចេញទៅបោះឆ្នោតរហូតដល់ ៨៤,៥៩% គឺមានចំនួនច្រើនជាងការបោះឆ្នោតមុនៗ។ អ្នកសង្កេតការណ៍អន្តរជាតិ មានជាង ៤០០ នាក់។

ចំពោះការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនថា មាន ៤ ថ្នាក់ គឺនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) នៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចុងក្រោយនៅក្រុមប្រឹក្សាធម្មនុញ្ញ។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនផងដែរអំពីការអប់រំអ្នកបោះឆ្នោត ការផ្សព្វផ្សាយព័ត៌មានជូនអ្នកបោះឆ្នោត និងការចូលរួមរបស់ភាគីពាក់ព័ន្ធនឹងការបោះឆ្នោត រួមមាន គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ។ល។ ឯកឧត្តមបន្តថា ការរៀបចំតាក់តែងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត គ.ជ.ប បានដាក់ជូនឱ្យភាគីពាក់ព័ន្ធចូលរួមផ្តល់អនុសាសន៍។ បន្ទាប់មក គ.ជ.ប ពិនិត្យលើអនុសាសន៍ទាំងនោះ



**សកម្មភាពថតរូបអនុស្សាវរីយ៍**

ចំណុចខ្លះ គ.ជ.ប ទទួលយក។ ចំពោះចំណុចដែលមិនទទួលយក គ.ជ.ប ឆ្លើយប្រាប់ជូនហេតុផលទៅភាគីពាក់ព័ន្ធទាំងនោះវិញ។ បន្ទាប់មកបទបញ្ជា និងនីតិវិធីនេះ ត្រូវបានអនុម័តដោយ គ.ជ.ប ដើម្បីអនុវត្តទាំងអស់គ្នា។

ជារួម គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតឱ្យប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការបោះឆ្នោត។ ម្យ៉ាងទៀត ការបោះឆ្នោតនៅកម្ពុជា គឺមានការវិវឌ្ឍពីមួយអាណត្តិទៅមួយអាណត្តិ ដោយបានបញ្ចូលបច្ចេកវិទ្យាព័ត៌មានទៅក្នុងដំណើរការរៀបចំការបោះឆ្នោត។

ជាថ្មីម្តងទៀត ឯកឧត្តម **រ៉េម៉ាន់ដូ ភីរ៉ោ** បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា បានទទួលគណៈប្រតិភូអន្តរជាតិយ៉ាងកក់ក្តៅ និងថ្លែងអំណរគុណដល់ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ដែលបានពន្យល់យ៉ាងក្បោះក្បាយ។

ជាចុងក្រោយ ឯកឧត្តម **ប្រាជ្ញ ចន្ទ** មានប្រសាសន៍ថា គ.ជ.ប កម្ពុជា មានកិច្ចសហការជាមួយអង្គការរៀបចំការបោះឆ្នោតនៅតាមបណ្តាប្រទេសនានាជាច្រើន ប្រសិនបើអង្គការស៊ីឌីអេអូ (CEDEAO) មានកិច្ចសហប្រតិបត្តិការពាក់ព័ន្ធការបោះឆ្នោតជាមួយ គ.ជ.ប កម្ពុជា គឺរឹតតែប្រសើរថែមទៀត។

អំពីប្រវត្តិ ឯកឧត្តម **រ៉េម៉ាន់ដូ ភីរ៉ោ** គឺធ្លាប់ជាអតីតប្រមុខសាធារណរដ្ឋស្តីទីនៃប្រទេស Guinea Bissau ដែលជារដ្ឋអាហ្វ្រិកខាងលិច មានទីតាំងភូមិសាស្ត្រស្ថិតនៅទ្វីបអាហ្វ្រិក។ ប្រទេសនេះ មានប្រជាពលរដ្ឋជាង ២,១៣ លាននាក់ ក្នុងឆ្នាំ២០២៣ និងប្រើប្រាស់ភាសាផ្លូវការគឺ Portuguese៕

# លទ្ធផលនៃការបែងចែកអាសនៈក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ តាមមណ្ឌលរាជធានី ខេត្ត

ផ្អែកតាមលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានផ្តល់សុពលភាព និងប្រកាសផ្សាយជាសាធារណៈ ក្នុងចំណោមអាសនៈក្នុងរដ្ឋសភាសរុបចំនួន ១២៥ គណបក្សប្រជាជនកម្ពុជា បានទទួលអាសនៈសរុបចំនួន ១២០ និងគណបក្សហ៊្វុនស៊ិនប៉ិច បានទទួលអាសនៈសរុបចំនួន ៥ តាមមណ្ឌលបោះឆ្នោត ដូចខាងក្រោម៖

០១- **មណ្ឌលខេត្តបន្ទាយមានជ័យ** : ក្នុងចំនួនអាសនៈរួម ៦ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

០២- **មណ្ឌលខេត្តបាត់ដំបង** : ក្នុងចំនួនអាសនៈរួម ៨ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

០៣- **មណ្ឌលខេត្តកំពង់ចាម** : ក្នុងចំនួនអាសនៈរួម ១០ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៩ អាសនៈ និងគណបក្សហ៊្វុនស៊ិនប៉ិច ១ អាសនៈ

០៤- **មណ្ឌលខេត្តកំពង់ឆ្នាំង** : ក្នុងចំនួនអាសនៈរួម ៤ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

០៥- **មណ្ឌលខេត្តកំពង់ស្ពឺ** : ក្នុងចំនួនអាសនៈរួម ៦ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

០៦- **មណ្ឌលខេត្តកំពង់ធំ** : ក្នុងចំនួនអាសនៈរួម ៦ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៥ អាសនៈ និងគណបក្សហ៊្វុនស៊ិនប៉ិច ១ អាសនៈ

០៧- **មណ្ឌលខេត្តកំពត** : ក្នុងចំនួនអាសនៈរួម ៦ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

០៨- **មណ្ឌលខេត្តកណ្តាល** : ក្នុងចំនួនអាសនៈរួម ១១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ១០ អាសនៈ និងគណបក្សហ៊្វុនស៊ិនប៉ិច ១ អាសនៈ

០៩- **មណ្ឌលខេត្តកោះកុង** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១០- **មណ្ឌលខេត្តក្រចេះ** : ក្នុងចំនួនអាសនៈរួម ៣ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១១- **មណ្ឌលខេត្តមណ្ឌលគិរី** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១២- **មណ្ឌលរាជធានីភ្នំពេញ** : ក្នុងចំនួនអាសនៈរួម ១២ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ១១ អាសនៈ និងគណបក្សហ៊្វុនស៊ិនប៉ិច ១ អាសនៈ

១៣- **មណ្ឌលខេត្តព្រះវិហារ** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១៤- **មណ្ឌលខេត្តព្រៃវែង** : ក្នុងចំនួនអាសនៈរួម ១១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ១០ អាសនៈ និងគណបក្សហ៊្វុនស៊ិនប៉ិច ១ អាសនៈ

១៥- **មណ្ឌលខេត្តពោធិ៍សាត់** : ក្នុងចំនួនអាសនៈរួម ៤ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១៦- **មណ្ឌលខេត្តរតនគិរី** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១៧- **មណ្ឌលខេត្តសៀមរាប** : ក្នុងចំនួនអាសនៈរួម ៦ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១៨- **មណ្ឌលខេត្តព្រះសីហនុ** : ក្នុងចំនួនអាសនៈរួម ៣ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

១៩- **មណ្ឌលខេត្តស្ទឹងត្រែង** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

២០- **មណ្ឌលខេត្តស្វាយរៀង** : ក្នុងចំនួនអាសនៈរួម ៥ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

២១- **មណ្ឌលខេត្តតាកែវ** : ក្នុងចំនួនអាសនៈរួម ៨ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

២២- **មណ្ឌលខេត្តកែប** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

២៣- **មណ្ឌលខេត្តប៉ៃលិន** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

២៤- **មណ្ឌលខេត្តឧត្តរមានជ័យ** : ក្នុងចំនួនអាសនៈរួម ១ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា

២៥- **មណ្ឌលខេត្តត្បូងឃ្មុំ** : ក្នុងចំនួនអាសនៈរួម ៨ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៕

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## បញ្ជីរាយនាមបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ នីតិកាលទី៧

ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

| ឈ្មោះមណ្ឌល | ល.រ | គោត្តនាម និងនាម | | | ភេទ | ថ្ងៃខែឆ្នាំកំណើត | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ០១. មណ្ឌលខេត្ត បន្ទាយមានជ័យ | | | | | | | |
| | ១ | ឯកឧត្តម | កែ | គឹមយ៉ាន | ប្រុស | ២៥-០២-១៩៥៥ | |
| | ២ | ឯកឧត្តម | គោស៊ុំ | សារឿត | ប្រុស | ០១-០៦-១៩៥៦ | |
| | ៣ | ឯកឧត្តម | អ៊ី | ឡុង | ប្រុស | ១១-០២-១៩៥៤ | |
| | ៤ | លោកជំទាវ | នួម | សុភ័ណ | ស្រី | ០៣-០១-១៩៥៥ | |
| | ៥ | ឯកឧត្តម | សេរី | កុសល | ប្រុស | ១២-១០-១៩៥៣ | |
| | ៦ | ឯកឧត្តម | ខេង | ស៊ុម | ប្រុស | ១៤-០៧-១៩៥៤ | |
| ០២. មណ្ឌលខេត្ត បាត់ដំបង | | | | | | | |
| | ៧ | សម្តេច | ស | ខេង | ប្រុស | ១៥-០១-១៩៥១ | |
| | ៨ | ឯកឧត្តម | ងិន | ឃន | ប្រុស | ០៩-០២-១៩៥១ | |
| | ៩ | ឯកឧត្តម | ឡោក | ហ៊ួរ | ប្រុស | ០៩-០១-១៩៦៣ | |
| | ១០ | ឯកឧត្តម | អង្គ | វង្ស វឌ្ឍានា | ប្រុស | ២០-០៣-១៩៤៩ | |
| | ១១ | ឯកឧត្តម | ឈាង | វុន | ប្រុស | ២០-០១-១៩៥១ | |
| | ១២ | ឯកឧត្តម | កើត | រិទ្ធ | ប្រុស | ០២-០១-១៩៧៩ | |
| | ១៣ | ឯកឧត្តម | សក់ | សេដ្ឋា | ប្រុស | ១៥-០៥-១៩៥៦ | |
| | ១៤ | ឯកឧត្តម | ច័ន្ទ | សុផល | ប្រុស | ០៩-០៩-១៩៥៧ | |
| ០៣. មណ្ឌលខេត្ត កំពង់ចាម | | | | | | | |
| | ១៥ | ឯកឧត្តម | យឹម | ឆៃលី | ប្រុស | ១៥-០៥-១៩៥០ | |
| | ១៦ | ឯកឧត្តម | ខៀវ | កាញារីទ្ធ | ប្រុស | ១៣-០៩-១៩៥១ | |
| | ១៧ | ឯកឧត្តម | ប៉ាន | សូរស័ក្តិ | ប្រុស | ៣០-១០-១៩៥៥ | |
| | ១៨ | ឯកឧត្តម | វេង | សាខុន | ប្រុស | ០៥-០៨-១៩៦០ | |
| | ១៩ | ឯកឧត្តម | ហង់ជួន | ណារ៉ុន | ប្រុស | ០២-០១-១៩៦២ | |
| | ២០ | ឯកឧត្តម | លូ | គឹមឈន់ | ប្រុស | ១១-០៣-១៩៥៦ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២១ | ឯកឧត្តម | លន់ | លឹមថៃ | ប្រុស | ០៩-០៤-១៩៥៧ | |
| | ២២ | ឯកឧត្តម | ងួន | សុជាតិ | ប្រុស | ១៦-០៩-១៩៧១ | |
| | ២៣ | ឯកឧត្តម | ម៉ា | ឈឿន | ប្រុស | ១៥-០៣-១៩៥៤ | |
| | ២៤ | ឯកឧត្តម | ញៀន | រ៉ាដែន | ប្រុស | ០៤-០២-១៩៨៦ | |
| ០៤. មណ្ឌលខេត្ត កំពង់ឆ្នាំង | | | | | | | |
| | ២៥ | សម្ដេច | គង់ | សំអុល | ប្រុស | ០១-១១-១៩៣៦ | |
| | ២៦ | ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | ប្រុស | ២៧-០១-១៩៥១ | |
| | ២៧ | លោកជំទាវ | កែ | ច័ន្ទមុនី | ស្រី | ០១-០៥-១៩៥៩ | |
| | ២៨ | ឯកឧត្តម | លី | ណារុន | ប្រុស | ០៣-០៣-១៩៦១ | |
| ០៥. មណ្ឌលខេត្ត កំពង់ស្ពឺ | | | | | | | |
| | ២៩ | ឯកឧត្តម | ឆាយ | ថន | ប្រុស | ២១-១០-១៩៤៧ | |
| | ៣០ | ឯកឧត្តម | ហ៊ុន | ម៉ានី | ប្រុស | ២៧-១១-១៩៨២ | |
| | ៣១ | ឯកឧត្តម | សត្យា | វុធ | ប្រុស | ០១-០១-១៩៥៤ | |
| | ៣២ | ឯកឧត្តម | សេង | ញ៉ក់ | ប្រុស | ១៥-០១-១៩៨០ | |
| | ៣៣ | លោកជំទាវ | ខេង | សំវ៉ាដា | ស្រី | ២២-១១-១៩៥៦ | |
| | ៣៤ | ឯកឧត្តម | សុខ | បិន | ប្រុស | ១៨-០២-១៩៥២ | |
| ០៦. មណ្ឌលខេត្ត កំពង់ធំ | | | | | | | |
| | ៣៥ | ឯកឧត្តម | ជា | ចាន់តូ | ប្រុស | ០៩-១០-១៩៥១ | |
| | ៣៦ | ឯកឧត្តម | ថោង | ខុន | ប្រុស | ២៣-១១-១៩៥១ | |
| | ៣៧ | ឯកឧត្តម | ស្វស | យ៉ារ៉ា | ប្រុស | ១៨-១១-១៩៧៣ | |
| | ៣៨ | ឯកឧត្តម | ឃឹង | នុភាព | ប្រុស | ១៥-០២-១៩៧៩ | |
| | ៣៩ | ឯកឧត្តម | នង | វាសនា | ប្រុស | ០៩-០៦-១៩៨២ | |
| | ៤០ | ឯកឧត្តម | នាង | ចាន់ណាក់ | ប្រុស | ១០-១០-១៩៨៣ | |
| ០៧. មណ្ឌលខេត្ត កំពត | | | | | | | |
| | ៤១ | ឯកឧត្តម | ប៉ែន | ស៊ីម៉ន | ប្រុស | ១៥-០៩-១៩៥៤ | |
| | ៤២ | លោកជំទាវ | អ៊ិន | សុគន្ធា | ស្រី | ១៥-០៣-១៩៥៥ | |
| | ៤៣ | ឯកឧត្តម | សោម | ចិន | ប្រុស | ០១-០៩-១៩៥៨ | |
| | ៤៤ | ឯកឧត្តម | នឹម | ច័ន្ទតារា | ប្រុស | ២៨-០៨-១៩៥៤ | |
| | ៤៥ | លោកជំទាវ | ចម | និម្មល | ស្រី | ១៨-០៥-១៩៨០ | |
| | ៤៦ | ឯកឧត្តម | ម៉ាត់ | សេត | ប្រុស | ២១-១០-១៩៨០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **០៨. មណ្ឌលខេត្ត កណ្ដាល** | | | | | | | |
| | ៤៧ | សម្ដេច | ហ៊ុន | សែន | ប្រុស | ០៥-០៨-១៩៥២ | |
| | ៤៨ | លោកជំទាវ | ឃួន | សុដារី | ស្រី | ១៨-១១-១៩៥២ | |
| | ៤៩ | ឯកឧត្តម | អួន | ព័ន្ធមុនីរ័ត្ន | ប្រុស | ០១-១០-១៩៦៥ | |
| | ៥០ | ឯកឧត្តម | ប្រាក់ | សុខុន | ប្រុស | ០៣-០៥-១៩៥៤ | |
| | ៥១ | ឯកឧត្តម | ម៉ៅ | ភិរុណ | ប្រុស | ២៣-០៣-១៩៦០ | |
| | ៥២ | ឯកឧត្តម | ស៊ិន | ចាន់ថុល | ប្រុស | ៣០-០៦-១៩៥៦ | |
| | ៥៣ | ឯកឧត្តម | លឹម | គានហោ | ប្រុស | ២៧-០៥-១៩៥០ | |
| | ៥៤ | ឯកឧត្តម | សុខ | ចិន្ដាសោភា | ប្រុស | ២៧-០៤-១៩៥៦ | |
| | ៥៥ | ឯកឧត្តម | វង្សី | វិស្សុត | ប្រុស | ១៨-០២-១៩៦៥ | |
| | ៥៦ | ឯកឧត្តម | ទី | សុគន្ធ | ប្រុស | ០៧-០៥-១៩៦៧ | |
| | ៥៧ | ឯកឧត្តម | គង់ | បណ្ឌូល | ប្រុស | ០៨-០៤-១៩៧៥ | |
| **០៩. មណ្ឌលខេត្ត កោះកុង** | | | | | | | |
| | ៥៨ | ឯកឧត្តម | ជុំ | យុហៀន | ប្រុស | ០៥-០៨-១៩៥២ | |
| **១០. មណ្ឌលខេត្ត ក្រចេះ** | | | | | | | |
| | ៥៩ | ឯកឧត្តម | ព្រុំ | សុខា | ប្រុស | ០២-១២-១៩៥៤ | |
| | ៦០ | ឯកឧត្តម | ពេជ្រ | ប៊ុនធិន | ប្រុស | ០១-១០-១៩៤៤ | |
| | ៦១ | ឯកឧត្តម | សរ | ចំរុង | ប្រុស | ០៣-០៥-១៩៥៨ | |
| **១១. មណ្ឌលខេត្ត មណ្ឌលគិរី** | | | | | | | |
| | ៦២ | ឯកឧត្តម | ចាន់ | យឿន | ប្រុស | ១៥-០២-១៩៥១ | |
| **១២. មណ្ឌលរាជធានី ភ្នំពេញ** | | | | | | | |
| | ៦៣ | ឯកឧត្តម | ហ៊ុន | ម៉ាណែត | ប្រុស | ២០-១០-១៩៧៧ | |
| | ៦៤ | ឯកឧត្តម | ប៉ា | សុជាតិវង្ស | ប្រុស | ០១-០៧-១៩៥៧ | |
| | ៦៥ | ឯកឧត្តម | អ៊ិត | សំហេង | ប្រុស | ០១-០៨-១៩៥៨ | |
| | ៦៦ | ឯកឧត្តម | ម៉ម | ប៊ុនហេង | ប្រុស | ១៣-០៨-១៩៤៩ | |
| | ៦៧ | លោកជំទាវ | អ៊ឹង | កន្ថាផាវី | ស្រី | ១៦-០៧-១៩៦០ | |
| | ៦៨ | ឯកឧត្តម | កែប | ជុតិមា | ប្រុស | ០៧-០២-១៩៥១ | |
| | ៦៩ | លោកជំទាវ | ឡោក | ខេង | ស្រី | ២៥-០៣-១៩៥៥ | |
| | ៧០ | លោកជំទាវ | គ្រួច | សំអាន | ស្រី | ២៦-០៥-១៩៥៣ | |
| | ៧១ | ឯកឧត្តម | អូស្មាន | ហាស្សាន់ | ប្រុស | ១០-០១-១៩៥៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៧២ | ឯកឧត្តម | ឃុត | ចាន់ដារ៉ា | ប្រុស | ៣០-១២-១៩៨០ | |
| | ៧៣ | ឯកឧត្តម | លី | ឆេង | ប្រុស | ០៥-០៦-១៩៥៦ | |
| | ៧៤ | ព្រះអង្គម្ចាស់ | នរោត្តម | ចក្រាវុធ | ប្រុស | ១៣-០១-១៩៧០ | |
| **១៣. មណ្ឌលខេត្ត ព្រះវិហារ** | | | | | | | |
| | ៧៥ | ឯកឧត្តម | មាស | សុភា | ប្រុស | ០៩-០៤-១៩៥៥ | |
| **១៤. មណ្ឌលខេត្ត ព្រៃវែង** | | | | | | | |
| | ៧៦ | ឯកឧត្តម | ជាម | យៀប | ប្រុស | ២២-១០-១៩៤៦ | |
| | ៧៧ | ឯកឧត្តម | ស | សុខា | ប្រុស | ០៤-០៦-១៩៨១ | |
| | ៧៨ | ឯកឧត្តម | ម៉ុម | ស៊ីប៊ុន | ប្រុស | ២៥-០៧-១៩៤៤ | |
| | ៧៩ | ឯកឧត្តម | ឡុង | ប៊ុន្នី | ប្រុស | ១០-០៣-១៩៧០ | |
| | ៨០ | ឯកឧត្តម | ជាម | ប៉េអា | ប្រុស | ០៥-០៨-១៩៧៥ | |
| | ៨១ | ឯកឧត្តម | ញឹម | វណ្ណដា | ប្រុស | ១២-០៧-១៩៤៨ | |
| | ៨២ | ឯកឧត្តម | ស្បោង | សារ៉ាត | ប្រុស | ១៧-០៤-១៩៥៤ | |
| | ៨៣ | ឯកឧត្តម | ហ៊ី | បាវី | ប្រុស | ០៧-០៩-១៩៥៥ | |
| | ៨៤ | លោកជំទាវ | គង់ | សាឡូន | ស្រី | ០៦-០៤-១៩៥៤ | |
| | ៨៥ | ឯកឧត្តម | អ៊ុក | សិទ្ធិជាតិ | ប្រុស | ៣០-០១-១៩៦៩ | |
| | ៨៦ | ឯកឧត្តម | ភឹម | រ៉ុង | ប្រុស | ១៥-០១-១៩៧១ | |
| **១៥. មណ្ឌលខេត្ត ពោធិ៍សាត់** | | | | | | | |
| | ៨៧ | ឯកឧត្តម | ស៊ុយ | សែម | ប្រុស | ២៥-០៨-១៩៤៧ | |
| | ៨៨ | ឯកឧត្តម | កែវ | រតនៈ | ប្រុស | ១៦-០៩-១៩៧៣ | |
| | ៨៩ | ឯកឧត្តម | ទី | ថានី | ប្រុស | ១៣-០៤-១៩៥៩ | |
| | ៩០ | ឯកឧត្តម | កែវ | វីរៈ | ប្រុស | ១២-០៥-១៩៦៤ | |
| **១៦. មណ្ឌលខេត្ត រតនគិរី** | | | | | | | |
| | ៩១ | ឯកឧត្តម | គិត | ទ្រី | ប្រុស | ០៧-០៥-១៩៦៩ | |
| **១៧. មណ្ឌលខេត្ត សៀមរាប** | | | | | | | |
| | ៩២ | សម្តេច | ទៀ | បាញ់ | ប្រុស | ០៥-១១-១៩៤៥ | |
| | ៩៣ | ឯកឧត្តម | សៀង | ណាំ | ប្រុស | ១៦-១២-១៩៥៧ | |
| | ៩៤ | ឯកឧត្តម | ទៀ | សីហា | ប្រុស | ៣១-០៨-១៩៨០ | |
| | ៩៥ | លោកជំទាវ | តឹករ៉េត | កំរង | ស្រី | ១៥-១២-១៩៧២ | |
| | ៩៦ | ឯកឧត្តម | ឈឹម | ម៉ា | ប្រុស | ១២-០៣-១៩៥៧ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៩៧ | ឯកឧត្តម | នូ | ផល្លា | ប្រុស | ២៨-០១-១៩៥៤ | |
| ១៨. មណ្ឌលខេត្ត ព្រះសីហនុ | | | | | | | |
| | ៩៨ | ឯកឧត្តម | សាយ | សំអាល់ | ប្រុស | ១៥-០៥-១៩៨០ | |
| | ៩៩ | ឯកឧត្តម | តឹករ៉េត | សំរេច | ប្រុស | ០៦-០១-១៩៦៨ | |
| | ១០០ | ឯកឧត្តម | សូ | ខនឫទ្ធីគុណ | ប្រុស | ១០-០៨-១៩៦៩ | |
| ១៩. មណ្ឌលខេត្ត ស្ទឹងត្រែង | | | | | | | |
| | ១០១ | ឯកឧត្តម | ឡូយ | សុផាត | ប្រុស | ០៦-០៣-១៩៨៩ | |
| ២០. មណ្ឌលខេត្ត ស្វាយរៀង | | | | | | | |
| | ១០២ | សម្តេច | ម៉ែន | សំអន | ស្រី | ១៥-០៨-១៩៥៣ | |
| | ១០៣ | លោកជំទាវ | ដួង | វណ្ណា | ស្រី | ០១-០១-១៩៥៣ | |
| | ១០៤ | ឯកឧត្តម | ជ័យ | សុន | ប្រុស | ០៥-០១-១៩៥៤ | |
| | ១០៥ | ឯកឧត្តម | សម | តារា | ប្រុស | ១៩-០៨-១៩៦៨ | |
| | ១០៦ | លោកជំទាវ | ឯក | សុវណ្ណភារៈ | ស្រី | ១៣-០៣-១៩៦៨ | |
| ២១. មណ្ឌលខេត្ត តាកែវ | | | | | | | |
| | ១០៧ | ឯកឧត្តម | ប៊ិន | ឈិន | ប្រុស | ១៧-០៨-១៩៤៩ | |
| | ១០៨ | ឯកឧត្តម | ជា | វ៉ាន់ដេត | ប្រុស | ០២-០៨-១៩៧១ | |
| | ១០៩ | លោកជំទាវ | និន | សាផុន | ស្រី | ០៦-០៧-១៩៤៨ | |
| | ១១០ | ឯកឧត្តម | ម៉ុក | ម៉ារ៉េត | ប្រុស | ២០-០១-១៩៤៨ | |
| | ១១១ | ឯកឧត្តម | ស៊ូ | ភិរិន្ទ | ប្រុស | ២០-០៩-១៩៥២ | |
| | ១១២ | ឯកឧត្តម | ច័ន្ទ | សារុន | ប្រុស | ១៨-០៣-១៩៤៨ | |
| | ១១៣ | ឯកឧត្តម | អ៊ិត | សុខ | ប្រុស | ០១-១០-១៩៥៣ | |
| | ១១៤ | លោកជំទាវ | នូ | សុវណ្ណនី | ស្រី | ១៨-០៨-១៩៥៧ | |
| ២២. មណ្ឌលខេត្ត កែប | | | | | | | |
| | ១១៥ | ឯកឧត្តម | ចម | ប្រសិទ្ធ | ប្រុស | ១៥-០៥-១៩៥១ | |
| ២៣. មណ្ឌលខេត្ត ប៉ៃលិន | | | | | | | |
| | ១១៦ | ឯកឧត្តម | អ៊ី | ឈាន | ប្រុស | ១៣-០៨-១៩៥២ | |
| ២៤. មណ្ឌលខេត្ត ឧត្តរមានជ័យ | | | | | | | |
| | ១១៧ | ឯកឧត្តម | គន់ | គីម | ប្រុស | ០១-០១-១៩៥៤ | |
| ២៥. មណ្ឌលខេត្ត ត្បូងឃ្មុំ | | | | | | | |
| | ១១៨ | សម្តេច | ហេង | សំរិន | ប្រុស | ២៥-០៥-១៩៣៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១១៩ | ឯកឧត្តម | ជា | សុផារ៉ា | ប្រុស | ០១-០២-១៩៥២ | |
| | ១២០ | ឯកឧត្តម | វង | សូត | ប្រុស | ០៣-០៣-១៩៥៦ | |
| | ១២១ | ឯកឧត្តម | អ៊ាង | សុផល្លែត | ប្រុស | ១០-១០-១៩៦៩ | |
| | ១២២ | ឯកឧត្តម | ចាយ | បូរិន | ប្រុស | ០១-១១-១៩៧២ | |
| | ១២៣ | ឯកឧត្តម | ឌិត | ទីណា | ប្រុស | ០៧-០១-១៩៧៩ | |
| | ១២៤ | ឯកឧត្តម | កែវ | ពិសិដ្ឋ | ប្រុស | ១៨-០៣-១៩៦៩ | |
| | ១២៥ | ឯកឧត្តម | ឆាយ | ឫទ្ធិសែន | ប្រុស | ១០-១២-១៩៦៩ | |

ថ្ងៃសៅរ៍ ៤រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ សីហា ឆ្នាំ២០២៣
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ប្រាជ្ញ ចន្ទ

# លទ្ធផលសវនាការជាសាធារណៈដោះស្រាយពាក្យបណ្ដឹងតវ៉ា នៅនឹងសេចក្ដីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម ខេត្តប៉ៃលិន និងខេត្តត្បូងឃ្មុំ

នាព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ នៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប ដែលមានសមាសភាព ៩ រូប ដឹកនាំដោយ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប និងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប បានបើកសវនាការជាសាធារណៈ ដើម្បីជំនុំជម្រះលើពាក្យបណ្ដឹង/សំណុំរឿង ចំនួន ៥ ដែលត្រូវបានប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្ត រួមមាន ខេត្តកំពង់ចាម ខេត្តប៉ៃលិន និងខេត្តត្បូងឃ្មុំ។



សកម្មភាពក្នុងសវនាការ

បណ្តឹងតវ៉ាទាំងនោះមានដូចខាងក្រោម៖

១. សំណុំរឿងលេខ ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ ដើមបណ្តឹងឈ្មោះ **លី ម៉េងហ៊ង** ភេទប្រុស កើតថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៨២ ប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០១ គ.ប/ក.ច ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ដែលបានផាកពិន័យខ្លួនជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។



**សកម្មភាពក្នុងសវនាការ**

២. សំណុំរឿងលេខ ០០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ដើមបណ្តឹងមេធាវីឈ្មោះ **ហេង វណ្ណបុត្រ** តំណាងឱ្យលោក **ហ៊ាន រចនា** កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៨០ ប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ដែលបានផាកពិន័យឈ្មោះ **ខឹម មុនីកុសល** ភេទប្រុស កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៣ ជាប្រាក់ ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ដែលការសម្រេចនេះមិនទៅតាមការចង់បានរបស់កូនក្តី (**ហ៊ាន រចនា**) ដែលស្នើសុំឱ្យដកសិទ្ធិឈរ



**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប**

ឈ្មោះឱ្យគេបោះឆ្នោតយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

៣. សំណុំរឿងលេខ ០០៣ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ដើមបណ្តឹងមេធាវីឈ្មោះ **ហេង វណ្ណបុត្រ** តំណាងឱ្យលោក **ហ៊ាន រចនា** កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៨០ ប្តឹងតវ៉ា ទៅនឹងសេចក្តីសម្រេចលេខ ០០២ គ.ប/ក.ច ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ដែលបានផាកពិន័យ ឈ្មោះ **ស៊ុន សុភា** ភេទស្រី កើតថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩៤ ជាប្រាក់ ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ដែលការសម្រេចនេះមិនទៅតាមការចង់បានរបស់



**គណៈលេខាធិការសវនាការ**

កូនក្តី (**ហ៊ាន រចនា**) ដែលស្នើសុំឱ្យដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត យ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

៤. សំណុំរឿងលេខ ០០៤ និងលេខ ០០៥ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣

- ដើមបណ្តឹងឈ្មោះ **យ៉ាន សុឃឿន** ភេទប្រុស កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៨២ ជាគ្រូបង្រៀន ប្តឹងត៍វ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០១ គ.ប/ត.ឃ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ដែលបានផាកពិន័យខ្លួន ជាប្រាក់ ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ។
- ដើមបណ្តឹងឈ្មោះ **ទូច ជីវ៉ា** ភេទប្រុស កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧២ ជាមេធាវី ប្តឹងត៍វ៉ាទៅនឹងសេចក្តីសម្រេចលេខ ០០១ គ.ប/ត.ឃ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ដែលបានផាកពិន័យឈ្មោះ **យ៉ាន សុឃឿន** ភេទប្រុស កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៨២ ជាប្រាក់ និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងដកសិទ្ធិបោះឆ្នោត មានលក្ខណៈធ្ងន់ស្រាល។

បន្ទាប់ពីបានស្តាប់ការឆ្លើយបំភ្លឺរបស់ដើមបណ្តឹង និងមេធាវីតំណាងចុងចម្លើយ ក្រោយពីបានពិនិត្យភស្តុតាង និងក្រោយពីបានពិភាក្សាស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររួចមក ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប សម្រេច៖

១. តម្កល់សេចក្តីសម្រេចលេខ ០០១ គ.ប/ក.ច ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចលេខ ០០១ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខដើមបណ្តឹង និងមេធាវីតំណាងគូភាគី បើកផ្លូវប្តឹងត៍វ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

២. តម្កល់សេចក្តីសម្រេចលេខ ០០១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចលេខ ០០២ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខមេធាវីតំណាងដើមបណ្តឹង និងកំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងត៍វ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

៣. តម្កល់សេចក្តីសម្រេចលេខ ០០២ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចលេខ ០០៣ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខមេធាវីដើមបណ្តឹង និងកំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ បើកផ្លូវ ប្តឹងត៍វ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

៤. តម្កល់សេចក្តីសម្រេចលេខ ០០១ គ.ប/ត.ឃ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ទុកជាបានការពេញទាំងមូល។ សេចក្តីសម្រេចលេខ ០០៤ គ.ជ.ប ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខដើមបណ្តឹង និង

មេធាវីតំណាងចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

ពាក្យបណ្តឹងទាំងអស់ខាងលើនេះ ពាក់ព័ន្ធទៅនឹងការណែនាំរារាំង ឬញុះញង់ប្រជាពលរដ្ឋមិនឱ្យទៅបោះឆ្នោត ឬឱ្យអ្នកបោះឆ្នោតគូសបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត ដែលជាអំពើល្មើស ដូចមានចែងក្នុងមាត្រា ១៤២ថ្មី ក្នុងមាត្រាពីរនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត៕

# គ.ជ.ប បានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជាក់ភាពត្រឹមត្រូវលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជាក់ភាពត្រឹមត្រូវលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ស្របតាមបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។ ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នេះ បានធ្វើឡើងនៅទីស្តីការ គ.ជ.ប ដោយមានការចូលរួមសង្កេតមើលពីតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន។

ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវបែងចែកជា ៥ ក្រុម ដោយក្រុមនីមួយៗទទួលបន្ទុក ចំនួន ៥ មណ្ឌលបោះឆ្នោត និងធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតម្តងមួយមណ្ឌលៗ យ៉ាងល្អិតល្អន់ តាមប្រមាណវិធីដោយដៃ និងប្រព័ន្ធកុំព្យូទ័រ។ ដំណើរការនេះបានប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ នេះ។



សកម្មភាពត្រួតពិនិត្យ និងផ្ទៀងផ្ទាត់



សកម្មភាពត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

ជាលទ្ធផល ក្រុមត្រួតពិនិត្យ មិនបានរកឃើញកំហុស ឬភាពមិនប្រក្រតីណាមួយពាក់ព័ន្ធនឹងការគណនាតួលេខលទ្ធផលសំឡេងឆ្នោតគាំទ្រគណបក្សនយោបាយនីមួយៗ ដែលគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ទាំង ២៥ បានបញ្ជាក់ក្នុងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ឡើយ។

បន្ទាប់ពីបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជាក់អំពីភាពត្រឹមត្រូវរួចរាល់ លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នឹងត្រូវដាក់ជូនថ្នាក់ដឹកនាំ គ.ជ.ប ពិនិត្យ និងសម្រេច ដើម្បីធ្វើការប្រកាសផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ស្របតាមប្រតិទិននៃការបោះឆ្នោត៕

---

# ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយមានការចូលរួមសង្កេតមើលពីអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ជាច្រើនរូប

ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអនុវត្តការងាររៀបចំការបោះឆ្នោត អនុលោមតាមច្បាប់ បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត រួមនឹងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និងបានអនុញ្ញាតឱ្យភាគីពាក់ព័ន្ធនឹងការបោះឆ្នោត បានចូលរួមតាមដានសង្កេតមើលដំណើរការបោះឆ្នោត យ៉ាងទូលំទូលាយ។ ក្នុងនោះ គ.ជ.ប បានទទួលស្គាល់ និងផ្ដល់បណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិជាច្រើនរូប រួមមាន៖

- អ្នកសង្កេតការណ៍ជាតិ មានចំនួនសរុប ៨៩.៥៦២ រូប ស្ត្រីចំនួន ៥២.៦៥២ រូប មកពី ១៣៤ សមាគម អង្គការមិនមែនរដ្ឋាភិបាល
- អ្នកសង្កេតការណ៍អន្តរជាតិ មានចំនួនសរុប ៦០៤ រូប មកពី ៦១ ស្ថាប័ន ក្នុងនោះរួមមាន៖
    - ប្រតិភូអន្តរជាតិដែលអញ្ជើញដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ២៦៨ រូប មកពី ២៦ ស្ថាប័ន
    - ប្រតិភូអន្តរជាតិដែលអញ្ជើញដោយវេទិកាសម្ព័ន្ធសង្គមស៊ីវិល ចំនួន ៦៥ រូប មកពី ១២ ស្ថាប័ន
    - ប្រតិភូអន្តរជាតិដែលអញ្ជើញដោយ គ.ជ.ប ចំនួន ២៤ រូប
    - អ្នកសង្កេតការណ៍អន្តរជាតិ ដែលស្នើសុំដោយផ្ទាល់មក គ.ជ.ប ចំនួន ៤៧ រូប
    - ភ្ញៀវពិសេស ចំនួន ១៨ រូប (អញ្ជើញដោយ គ.ជ.ប ចំនួន ១១ រូប និងស្នើសុំដោយផ្ទាល់មក គ.ជ.ប ចំនួន ៧ រូប)
    - អ្នកបកប្រែសម្រាប់អ្នកសង្កេតការណ៍អន្តរជាតិ ចំនួន ១៨២ រូប។

(តារាងលម្អិត៖ www.nec.gov.kh/khmer/content/7207)

សូមបញ្ជាក់ជូនថា ក្រៅពីអ្នកសង្កេតការណ៍បោះឆ្នោតភ្នាក់ងារគណបក្សនយោបាយ និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាច្រើនបានចូលរួមតាមដាន សង្កេតមើលដំណើរការបោះឆ្នោតផងដែរ៕

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ទីស្ដីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីមែល(Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News